# ការកំហិតការប្រើប្រាស់ឯកសារក្នុងបំណាចផ្តាញ់សាក្សី

អាន ហាញឌុល

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១២

ប្រែសម្រួលដោយ លីម ជ័យទ័ត

រយៈពេលប៉ុន្មានខែថ្មីៗនេះ មានការដាក់សំណើ និងសេចក្តីសម្រេចជាច្រើនទាក់ទងនឹងឯកសារដែលយកមកបង្ហាញនៅចំពោះមុខសាក្សី ជាពិសេសឯកសារដែលប្រើប្រាស់ក្នុងគោលបំណងសួរដើម្បីផ្តាញ់សាក្សី ។ បញ្ហានេះត្រូវបានលើកឡើងនៅពេលដែលភាគីបានត្រៀមដើម្បីសាកសួរអ្នកជំនាញប្រវត្តិសាស្ត្រដែលមានភាពល្បីល្បាញ គឺលោក ដេវីដ ឆេនដល័រ ។

មុនពេលនៃការចាប់ផ្តើមសវនាការនៃសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីទាំងអស់ដាក់ជូននូវបញ្ជីឯកសារដែលខ្លួនមានបំណងចង់ដាក់នៅចំពោះអង្គជំនុំជម្រះធ្វើជាភស្តុតាង ។ អង្គជំនុំជម្រះបានព្យាយាមពន្លឿនកិច្ចដំណើរការនីតិវិធី ដោយធ្វើការកំណត់អត្តសញ្ញាណរាល់ភស្តុតាងសក្តានុពលដែលមិនមានការយល់ស្របគ្នា និងធ្វើការកំហិតការពិភាក្សាចំពោះការជំទាស់ទាក់ទងនឹងភស្តុតាងនោះ ។ ការអនុវត្តបែបនេះ ត្រូវបានចាត់ទុកថាជាភាពចាំបាច់មួយដែលត្រូវបត់បែនពីការអនុវត្តនូវបទដ្ឋានភាពអាចទទួលយកបាន នៃឯកសារដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយសារតែចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃឯកសារដែលប្រើប្រាស់នៅក្នុងសវនាការជំនុំជម្រះបទឧក្រិដ្ឋដែលមានទំហំធំធេង ។ សម្រាប់ហេតុផលនេះ អង្គជំនុំជម្រះបានច្រានចោលការលើកឡើងរបស់ក្រុមមេធាវីការពារក្តី ដែលអះអាងថា មិនមានការតម្រូវឲ្យដាក់បញ្ជីឯកសារជាមុនទេនៅក្រោមក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការប៉ុនប៉ងរបស់ខ្លួនក្នុងការធ្វើបញ្ជីឯកសារដែលមាននៅក្នុងសំណុំរឿង ឬនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ។ ក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងថា ៖

> ការដាក់ពេលវេលាកំណត់ ដែលមានភាពបត់បែនសម្រាប់ការកំណត់អត្តសញ្ញាណនៃឯកសារភស្តុតាងដែលដាក់ដោយភាគី អាចជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់គ្រប់គ្រងសំណុំរឿង...... មេធាវីការពារក្តីមិនបានដឹងអំពីយុត្តិសាស្ត្រណាមួយនៅលើពិភពលោក ដែលតម្រូវឲ្យជនជាប់ចោទដាក់បញ្ជីឯកសារដាច់ស្រេច (ដែលនឹងត្រូវដកចេញជាបន្តបន្ទាប់) ដើម្បីប្រើក្នុងសវនាការជាច្រើនខែនៅមុនពេលដំណើរការនីតិវិធីឡើយ ។ តាមការអនុវត្តជាក់ស្តែង វិធីសាស្ត្របែបនេះទាំងក្នុងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ គឺមិនអាចអនុវត្តបាន និងមិនមានយុត្តិធម៌ទេ ។

នៅខែឧសភា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបញ្ជាក់យ៉ាងច្បាស់ថា គ្រប់ឯកសារទាំងអស់ដែលធ្លាប់យកមកប្រើប្រាស់ដើម្បីសួរដេញសាក្សី ត្រូវតែឆ្លើយតបនឹងលក្ខខណ្ឌនៃភាពអាចទទួលយកបានដូចគ្នានឹងឯកសារភស្តុតាងដែលផ្អែកលើការពិតនៃខ្លឹមសាររបស់វា ដោយរាប់បញ្ចូលទាំងការលើកឡើងមុនៗដែលមាននៅក្នុងបញ្ជីរបស់ភាគីណាមួយ ។ ជាការពិត ការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ទាំងភស្តុតាងសារធាតុ និងឯកសារសម្រាប់សួរដេញ អាចត្រូវបានប្រើប្រាស់នៅក្នុងមធ្យោបាយដូចគ្នា ប៉ុន្តែច្រកសម្រាប់ទទួលយកឯកសារទាំងនេះគឺមានភាពតូចចង្អៀតណាស់ ។

ភាគីទាំងអស់បានលើកឡើងថា ការអនុញ្ញាតឲ្យមានការប្រើប្រាស់ដោយសេរីនូវឯកសារដើម្បីសួរដេញសាក្សី គឺជាការសមស្រប ។ ជាឧទាហរណ៍ សហព្រះរាជអាជ្ញា យល់ស្របថា......នៅក្នុងកាលៈទេសៈខ្លះអាចលើកឡើងបាន ប្រសិនបើឯកសារនោះមានភាពចាំបាច់ក្នុងការប្រើប្រាស់នៅពេលបន្ទាប់មក ទាក់ទងនឹងការសួរដេញដោលអំពីលក្ខណៈសម្បត្តិរបស់សាក្សី និងមិនជឿថា រាល់ឯកសារទាំងអស់ត្រូវតែដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះនោះទេ ។ ប៉ុន្តែ អង្គជំនុំជម្រះបានសម្រេចថា មធ្យោបាយតែមួយគត់ដែលភាគីអាចប្រើប្រាស់ឯកសារដែលមិនមាននៅក្នុងបញ្ជីឯកសារក្នុងគោលបំណងដើម្បីសួរដេញ លុះត្រាតែឯកសារនោះឆ្លើយតបនឹងភាពចាំបាច់ដែលតម្រូវឲ្យទទួលយកឯកសារនោះធ្វើជាភស្តុតាងថ្មី ។ រាប់បញ្ចូលនូវកាតព្វកិច្ចដើម្បីធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ។

ផ្ទុយមកវិញ ឯកសារទាំងនោះមិនអាចយកមកប្រើប្រាស់ដើម្បីសួរដេញសាក្សីបានទេ ប្រសិនបើឯកសារទាំងនោះធ្លាប់មាននៅលើបញ្ជីឯកសាររបស់ភាគីមួយនៅមុនពេលជំនុំជម្រះ ទោះបីជាឯកសារនោះដាក់ជូនទាន់ពេលវេលាកំណត់ក៏ដោយ ។ អង្គជំនុំជម្រះពិចារណាលើឯកសារទាំងអស់នេះ តែនៅពេលណាដែលអង្គជំនុំជម្រះចាត់ទុកឯកសារទាំងនេះថាជាឯកសារដោះបន្ទុក និងតម្រូវឲ្យមានការវាយតម្លៃ ដើម្បីបញ្ចៀសការសម្រេចដោយមិនមានភាពយុត្តិធម៌ ។ ក៏ប៉ុន្តែ ទោះបីមានកិច្ចដំណើរការនីតិវិធី៨ខែ ហើយក៏ដោយ ភាគីនៅតែមិនទាន់ស្គាល់អំពីអត្តសញ្ញាណរបស់សាក្សីទាំងអស់នៅឡើយ ។ ដូចដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើង ការត្រៀមរៀបចំសម្រាប់ការសួរឆ្លង គឺកំពុងបន្ត ហើយជាក់ស្តែង ដំណើរការនៃការប្រើប្រាស់ពេលវេលានៅមិនទាន់អាចបញ្ចប់នៅឡើយ (ឬមិនទាន់អាចលើកឡើងបាន សូម្បីចាប់ផ្តើមហើយក៏ដោយ) និងលុះត្រាតែវាត្រូវបានដឹងប្រាកដថា សាក្សីរូបណានឹងត្រូវបានកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងតុលាការ ។

វិធីសាស្ត្ររបស់អង្គជំនុំជម្រះ ទំនងជារារាំងមិនឲ្យភាគីប្រើប្រាស់ឯកសារដែលមិនបានត្រៀមរៀបចំ និងមិនមាននៅក្នុងបញ្ជីឯកសារ ដែលត្រៀមសម្រាប់គោលបំណងគោលផ្ទាញ់សាក្សី ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា "*សំណើភាគច្រើនដែលស្នើសុំឲ្យទទួលយកឯកសារដែលដាក់ជូនមិនទាន់ពេលវេលា ទំនងជានឹងមិនត្រូវបានទទួលយកឡើយ*"។ ថ្មីៗនេះ ក្រុមមេធាវីការពារក្ដី អៀង សារី បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងកំពុងអនុវត្តបទដ្ឋានដ៏តឹងរ៉ឹងគ្មានការបត់បែនទាក់ទងនឹងការប្រើប្រាស់ឯកសារ ដែលអាចនាំទៅដល់ការរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន ។ នេះគឺជាការឆ្លើយតបនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលថា អត្ថបទស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ មិនមែនស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យថាជា *ឯកសារថ្មី* ដោយសារឯកសារទាំងនោះស្ថិតនៅក្នុងវិស័យសាធារណៈចាប់តាំងពីឆ្នាំ១៩៨៩ ១៩៩៨ និងឆ្នាំ២០០០ ។

ក្រុមមេធាវីការពារក្ដី អៀង សារី បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនបានពន្យល់អំពីមូលហេតុដែលខ្លួនមិនចាត់ទុកឯកសារនោះស្ថិតក្នុងលក្ខណៈវិនិច្ឆ័យនៃ *ភស្តុតាងថ្មី* ទេ និងបានសង្កត់ធ្ងន់ថា "ជាច្រើនលើកច្រើនសាមកហើយ ភាពពាក់ព័ន្ធរបស់ឯកសារជាក់លាក់មួយ បានបង្ហាញឲ្យឃើញច្បាស់តែបន្ទាប់ពីពេលដែលឯកសារនោះត្រូវបានពិនិត្យដោយផ្អែកលើខ្លឹមសារពាក់ព័ន្ធរបស់វាជាមួយនឹងឯកសារដទៃទៀតតែប៉ុណ្ណោះ ។ ទោះបីជាឯកសារទាំងនេះ កើតឡើងមុនពេលចាប់ផ្ដើមជំនុំជម្រះក៏ដោយ ប៉ុន្តែនៅពេលនោះ យើងខ្ញុំពុំបានដឹងឡើយ ហើយក៏គ្មានឯកសារនោះដែរ ទោះបីជាយើងខ្ញុំបានបំពេញការងារដោយយកចិត្តទុកដាក់យ៉ាងណាក៏ដោយ "។ ក្រុមមេធាវីការពារក្ដី អៀង សារី ក៏បានបន្តសង្កត់ធ្ងន់ចំពោះ ការប្រព្រឹត្តមិនស្មើភាពគ្នាចំពោះភាគីដោយអង្គជំនុំជម្រះ ដោយសារតែអង្គជំនុំជម្រះបានទទួលយកសៀវភៅមួយក្បាល បោះពុម្ពនៅក្នុងឆ្នាំ២០១០ មកធ្វើជាភស្តុតាងចោទប្រកាន់ថ្មីក្នុងគោលបំណងនៃផលប្រយោជន៍យុត្តិធម៌ ទោះបីជាអង្គជំនុំជម្រះរកឃើញថា ព្រះរាជអាជ្ញា ខកខានមិនបានពន្យល់ពីមូលហេតុដែលពួកគេពុំអាចទទួលបានសៀវភៅនេះតាមរយៈការអនុវត្តដោយយកចិត្តទុកដាក់មុនពេលបើកសវនាការក៏ដោយ ។

នៅក្នុងការឆ្លើយតបលើកទីពីរចំពោះសំណើរបស់ក្រុមមេធាវីការពារក្ដី អៀង សារី អង្គជំនុំជម្រះបានសម្រេចចិត្តទទួលយកឯកសារដែលត្រូវបានជំទាស់ ដោយមិនមានការផ្លាស់ប្ដូរអ្វីទាំងអស់ គឺគ្រាន់តែមានការបោះពុម្ពផ្សេងគ្នានៃសៀវភៅដែលមាននៅក្នុងបញ្ជីរបស់ភាគីផ្សេងទៀត រួចហើយតែប៉ុណ្ណោះ និងផ្ដល់ហេតុផលថា "វាគឺជាផលប្រយោជន៍នៃយុត្តិធម៌ ដែលអនុញ្ញាតឲ្យមានសៀវភៅដែលមានការបោះពុម្ពផ្សេងគ្នាដើម្បីធ្វើការវាយតម្លៃរួមគ្នា "។ វាបានចង្អុលបង្ហាញថា សេចក្ដីសម្រេចនេះមានភាពស៊ីសង្វាក់គ្នាទាំងស្រុងជាមួយនឹងហេតុផលរបស់អង្គជំនុំជម្រះ នៅពេលដែលអង្គជំនុំជម្រះ

សម្រេចទទួលយកសំណើរបស់សហព្រះរាជអាជ្ញាដើម្បីដាក់សៀវភៅដែលបានបោះពុម្ពក្នុងឆ្នាំ២០១០ ចូលទៅក្នុងសំណុំរឿង ខណៈពេលដែលសៀវភៅនេះមានភាពជាប់ទាក់ទងគ្នាយ៉ាងជិតស្និទជាមួយនឹងឯកសារដែលត្រូវបានទទួលយកពីពេលមុន ។

ពាក់ព័ន្ធនឹងឯកសារដែលមិនមាននៅក្នុងបញ្ជីរបស់ភាគី និងមិនត្រូវបានទទួលយកធ្វើជាភស្តុតាងថ្មី អង្គជំនុំជម្រះបានលើកឡើងថា មាតិកានៃឯកសារទាំងនោះអាចត្រូវបានយោង ប៉ុន្តែមិនមែនជាការដកស្រង់សម្តីទេ នៅពេលសាកសួរសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ប្រសិនបើឯកសារទាំងនោះត្រូវបានផ្តល់ជូនដល់តុលាការជាមុន ។ សេចក្តីសម្រេចនេះ បានបង្ហាញអំពីការទទួលស្គាល់របស់អង្គជំនុំជម្រះថា ការបង្កើតភាពបត់បែន គឺជាអ្វីដែលគេចង់បាន ។ បើមិនដូច្នេះទេ វានឹងអាចបន្ថែមភាពស្មុគស្មាញលើបញ្ហាដែលមានស្រាប់ ។ ហេតុនេះ ការអនុវត្តនៃវិធានទាក់ទងនឹងភស្តុតាងថ្មីទំនងជាមិនបានលើកទឹកចិត្តឲ្យមានការអនុវត្តដោយប្រសិទ្ធភាពទេ ប៉ុន្តែជំនួសមកវិញ គឺកាន់តែជំរុញឲ្យមានការជជែកពិភាក្សាវែងឆ្ងាយបន្តទៀត និងធ្វើឲ្យអង្គជំនុំជម្រះកាន់តែងាយរងគ្រោះដោយសារការចោទប្រកាន់អំពីភាពមិនស៊ីសង្វាក់គ្នាក្នុងការកំណត់របស់ខ្លួនចំពោះឯកសារមួយណាដែលជាឯកសារថ្មី ក្នុងការទទួលយកដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ។

**-ចប់-**